00432742

D97/14/4

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

**សំណុំរឿងព្រហ្មទណ្ឌលេខ៖** ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៣៥)

**នៅចំពោះមុខ៖**
ចៅក្រម ប្រាក់ គឹមសាន, ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម ន៉ី ធុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

**កាលបរិច្ឆេទ៖** ថ្ងៃទី២០ ខែមករា ឆ្នាំ២០១០

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 20 / 01 / 2010
ម៉ោង (Time/Heure): 10:20
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

---

## សាធារណៈ

## សេចក្តីសម្រេចលើសំណើបន្ទាន់របស់ជនត្រូវចោទ អៀង សារី សុំបន្ថែមចំនួនទំព័រ ដែលបានកំណត់សម្រាប់ពាក្យបណ្តឹងរបស់ជនត្រូវចោទ អៀង សារី ប្រឆាំងនឹងដីការបស់ ក.ស.ច.ស សម្រេចអំពីការអនុវត្តនៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវ ដែលបានស្គាល់ថាជា សហឧក្រិដ្ឋកម្មរួម

---

**<u>សហព្រះរាជអាជ្ញា៖</u>**
លោកស្រី ជា លាង
លោក Andrew CAYLEY

**<u>ជនត្រូវចោទ៖</u>**
អៀង សារី

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 20 / 01 / 2010
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

អង្គបុរេជំនុំជម្រះ * PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE * E.C.C.C * C.E.T.C

០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ៣៥)

លេខ/N: D97/14/4

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី៖**

ហុង គឹមសួន
ឡោ ជុនធី
នី ចាន់ឌី
គង់ ពិសី
យ៉ុង ផានិត
គឹម ម៉េងឃី
ម៉ុច សុវណ្ណារី
ស៊ិន សូវន
ជេត វណ្ណលី
ពេជ អង្គ
គង់ ហេង
សំ សុគង់
សុក សំអឿន

Silke STUDZINSKY
Martine JACQUIN
Philippe CANNONE
Pierre Olivier SUR
Elizabeth RABESANDRATANA
Olivier BAHOUGNE
David BLACKMAN
Annie DELAHAIE
FabienneTRUSSES-NAPROUS
Patrick BEAUDOIN
Marie GUIRAUD
Lyma NGUYEN
Mahdev MOHAN
Julien RIVET
Emmanuel ALTIT
Maria Stefania CATALETA
Charlotte PLANTIN
Pascal AUBOIN
Jan Ernest RASSEK

**ដើមបណ្តឹងរដ្ឋប្បវេណីគ្មានអ្នកតំណាង៖**

**សហមេធាវីការពារក្តីរបស់ជនត្រូវចោទ**

អាង ឧត្តម
Michael G.KARNAVAS

**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("**អ.វ.ត.ក**") បានទទួល "សំណើបន្ទាន់របស់ជនត្រូវចោទ អៀង សារី សុំបន្ថែមចំនួនទំព័រដែលបានកំណត់សម្រាប់បណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទ អៀង សារី ប្រឆាំងនឹងដីការបស់ ក.ស.ច.ស សម្រេចអំពីការអនុវត្តនៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវដែលបានស្គាល់ថាជា សហឧក្រិដ្ឋកម្មរួម" ដាក់ដោយសហមេធាវីការពារក្តីជនត្រូវចោទ កាលពីថ្ងៃទី១៥ ខែមករា ឆ្នាំ២០១០ ("សំណើសុំ")។

១. នៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១០ សហចៅក្រមស៊ើបអង្កេតបានចេញដីកាសម្រេចអំពីការអនុវត្តនៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវដែលបានស្គាល់ថាជា សហឧក្រិដ្ឋកម្មរួម ("ដីកា")[១]។ ដីកាត្រូវបានជូនដំណឹងដល់ភាគីនានា កាលពីថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០០៩។

២. នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០០៩ សហមេធាវីការពារក្តីជនត្រូវចោទបានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកា។

៣. នៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០១០ សហមេធាវីការពារក្តីជនត្រូវចោទបានដាក់សំណើសុំ។ សហមេធាវីការពារក្តីបានបង្ហាញ និងបានផ្តល់នូវភស្តុតាងដែលគួរសបញ្ជាក់ថា សហព្រះរាជអាជ្ញា និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណី មិនជំទាស់ទៅនឹងសំណើសុំនេះទេ[២]។

៤. តាមរយៈសំណើសុំ សហមេធាវីការពារក្តីជនត្រូវចោទស្នើសុំបន្ថែមចំនួនទំព័រដែលបានកំណត់សម្រាប់ពាក្យបណ្តឹងឧទ្ធរណ៍នេះ រហូតដល់ ៤០ ទំព័រ។

៥. អង្គបុរេជំនុំជម្រះសង្កេតឃើញថា នៅក្នុងសំណើសុំ សហមេធាវីការពារក្តីបានលើកឡើងថាមានករណីពិសេសដែលតម្រូវឲ្យបន្ថែមចំនួនទំព័រ ដែលបានកំណត់សម្រាប់ពាក្យបណ្តឹងឧទ្ធរណ៍នេះ ពីព្រោះបញ្ហានានាដែលនឹងត្រូវលើកឡើងមានភាពស្មុគ្រស្មាញ ហើយជាការ

[១] ដីកាសម្រេចអំពីការអនុវត្តនៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវ ដែលបានស្គាល់ថាជា សហឧក្រិដ្ឋកម្មរួម ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៩ ឯកសារ D97/13 ("ដីកា")។

[២] សំណើសុំ ជើងទំព័រលេខ៥។

សំខាន់ណាស់ដែលត្រូវសរសេរបញ្ជាក់បញ្ហាទាំងនេះឲ្យបានពេញលេញ ព្រោះថាការអនុវត្ត ការទទួលខុសត្រូវលើសហឧក្រិដ្ឋកម្មរួម មានផលប៉ះពាល់ខ្លាំងទៅលើកិច្ចដំណើរការនីតិវិធី នាពេលអនាគត។

៦. អនុលោមតាមវិធាន ៥.៤ នៃសេចក្តីណែនាំអនុវត្តរបស់ អ.វ.ត.ក (វិសោធនកម្មលើកទី៤) អង្គបុរេជំនុំជម្រះ នៅក្នុងករណីពិសេសអាចបន្ថែមចំនួនទំព័រដែលបានកំណត់តាមសំណើសុំ របស់អ្នកចូលរួម។

៧. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា នេះជាផលប្រយោជន៍របស់ជនត្រូវចោទដែលត្រូវលើក ឡើងពីបញ្ហានានាឲ្យបានពេញលេញ និងទូលំទូលាយតាមដែលអាចធ្វើបាន។ អង្គបុរេជំនុំ ជម្រះកត់សម្គាល់ឃើញថែមទៀតថា សំណើសុំត្រូវបានដាក់មុនពេលវេលាកំណត់បានកន្លង ផុតទៅ។

៨. អង្គបុរេជំនុំជម្រះមានភាពច្បាស់លាស់គ្រប់គ្រាន់តាមរយៈមូលហេតុនានា ដែលបានផ្តល់ឲ្យ សម្រាប់សំណើសុំ និងកត់សម្គាល់ឃើញថា ពុំមានការជំទាស់ពីសហព្រះរាជអាជ្ញា ឬពីមេធាវី តំណាងដើមបណ្តឹងរដ្ឋប្បវេណីទេ។

**ហេតុដូច្នេះ អង្គបុរេជំនុំជម្រះ:**

**យល់ព្រម** តាមសំណើសុំបន្ថែមចំនួនទំព័រដែលបានកំណត់សម្រាប់ពាក្យបណ្តឹងនេះ រហូតដល់ ៤០ ទំព័រ។

**ភ្នំពេញ ថ្ងៃទី ២០ ខែមករា ឆ្នាំ២០១០**

**ប្រធានអង្គបុរេជំនុំជម្រះ**

PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C. C.E.T.C.

**ប្រាក់ គឹមសាន**